# ភាពទាក់ទាញនៃរូបអាសគ្រាម ភាគទី១

អាល់ ម៉ូល័រ Al Mohler

សព្វថ្ងៃ រូបអាសគ្រាម (រូបភាពអាសអាភាស)គឺជាបញ្ហាដ៏ធំបំផុតមួយនៅក្នុងចំណោមដៃគូរស្នេហាជាច្រើន ក្នុងនោះរួមទាំងដៃគូរស្នេហាជាគ្រីស្ទបរិស័ទផងដែរ។

សព្វថ្ងៃនេះ រូបអាសគ្រាមគឺជាបញ្ហាសីលធម៌ដ៏ធំបំផុតមួយដែលពួកជំនុំបានប្រឈមមុខចំពោះ។ ឯការស្រើបស្រាលវិញ ក៏កើតមាននៅក្នុងផ្នែកជាច្រើននៅក្នុងវប្បធម៌ដែរ ដែលនេះធ្វើឲ្យយើងមានការពិបាកក្នុងការចៀសឲ្យផុតពីឥទ្ធិពលនៃរូបអាសគ្រាមដែលមាននៅក្នុងវប្បធម៌និងនៅក្នុងជីវិតរស់នៅប្រចាំថ្ងៃ។

ទោះជាដូច្នេះក្តី បញ្ហានៃអំពើបាបរបស់មនុស្សក៏ជាកត្តាមួយ ដែលមិនផ្លាស់ប្តូរបាន ចាប់តាំងពីគ្រាធ្លាក់ចុះ(អ័ដាម) រហូតដល់បច្ចុប្បន្ន។ នៅក្នុងព្រះគម្ពីរមិនបាននិយាយថាមនុស្សសព្វថ្ងៃមានការស្រើបស្រាលជាងមនុស្សពីមុន ឬងាយធ្លាក់ចុះទៅក្នុងសេចក្តីល្បួងនៅពេលមើលឃើញភាពសិចស៊ីជាងមនុស្សសម័យមុន ឬថាមនុស្សសម័យនេះងាយនឹងធ្លាក់ចូលទៅក្នុងភាពស្រើបស្រាលជាងមនុស្សជំនាន់មុននោះឡើយ។

ប៉ុន្តែគ្រាន់តែថា សម័យបច្ចុប្បន្នខុសពីសម័យពីមុនតាមរបៀបពីរយ៉ាង។ ទីមួយ សព្វថ្ងៃនេះ រូបអាសគ្រាមត្រូវបានគេផ្សព្វផ្សាយជាទូទៅ ក្នុងនោះរួមមានរូបភាពផ្សាយពាណិជ្ជកម្មផ្សេងៗ កន្លែងកំសាន្ត និងសកម្មភាពនៃការរស់នៅរាល់ថ្ងៃ។ អ្វីៗដែលអំឡុងពេល២ឬ៣ទសវត្សមុនត្រូវបានរាប់ទុកជាអំពើខុសច្បាប់ តែឥឡូវនេះបែរជាលេចឡើងនៅគ្រប់ទីកន្លែង ហើយត្រូវបានគេរាប់ថាជារឿងធម្មតាវិញ។

លក្ខណៈខុសគ្នាទីពីរគឺ សព្វថ្ងៃនេះ មនុស្សខ្លះបានរាប់ថារូបអាសគ្រាមគឺជាការដ៏ល្អសំរាប់វប្បធម៌។ បច្ចុប្បន្ននេះ តាមរបាយការណ៍បានឲ្យដឹងថា រូបអាសគ្រាមគឺជាមុខជំនួញធំបំផុតទី៧នៅក្នុងសង្គមអាមេរិក។

លទ្ធផលដែលបានមកពីការកើនឡើងទាំងពីរករណីនេះគឺ មនុស្សបានមើលឃើញរូបភាពស្រើបស្រាលច្រើនជាងមុន ហើយនេះនាំឲ្យគេត្រូវការមើលឃើញរូបភាពស្រើបស្រាលបន្ថែមទៀតពីព្រោះរូបភាពស្រើបស្រាលធ្វើឲ្យចំណង់របស់មនុស្សមានកំលាំងកាន់តែខ្លាំងឡើងៗ ហើយរូបភាពអាសអាភាសដែលពីមុនបាននាំគេមានអារម្មណ៍ស្រើបស្រាល ពេលនេះលែងមានប្រសិទ្ធិភាពទៀតហើយ ដូច្នេះគេស្វែងរករូបអាសគ្រាមអនាចារជាងមុន។

រូបអាសអាភាសគឺជាបញ្ហាដ៏ធំ ជាពិសេសពាក់ព័ន្ធជាមួយនិងបុរស។ មានន័យថា អស់ពួកអ្នកប្រើប្រាស់ រូបអាសអាភាសភាគច្រើនគឺជាមនុស្សប្រុស ក្នុងនោះមានក្មេងប្រុស ឬមនុស្សប្រុសតែម្តង។ មនុស្សប្រុសជាច្រើនបានចំណាយលុយនិងពេលវេលាយ៉ាងច្រើនដើម្បីស្វែងរក និងមើលរូបអាសគ្រាម ដើម្បីធ្វើឲ្យខ្លួនឯងមានអារម្មណ៍ស្រើបស្រាល។

តើហេតុអ្វីបានជារូបអាសអាភាសគឺជាមុខជំនួញដ៏ធំមួយ? ចំលើយគឺផ្អែកលើមូលដ្ឋាននៃសេចក្តីពិតពីរយ៉ាង។ ទីមួយ៖ ចំលើយសំខាន់បំផុតគឺបានយកចេញពីការយល់ដឹងនៅក្នុងព្រះគម្ពីរទាក់ទងនិងលក្ខណៈរបស់មនុស្សក្នុងនាមជាមនុស្សមានបាប។ គ្រប់ទាំងការល្អដែលមាននៅក្នុងមនុស្សបានពុករលួយដោយសារបាប ហើយបាបបានបន្តជះឥទ្ធិពលទៅលើគ្រប់ទាំងបែបផែននៃជីវិត។ សភាពដែលស្ថិតនៅតាមកំណើតដើមនៃលក្ខណុៈភេទគួរតែនាំឆ្ពោះទៅកាន់ភក្តីភាពនៃសម្ព័ន្ធមេត្រីនៅក្នុងជីវិតអាពាហ៍ពិពាហ៍ បានត្រឡប់ជាពុករលួយ ហើយភាពពុករលួយនៃការរួមភេទនេះបានផ្តល់នូវលទ្ធផលអាក្រក់នៅក្នុងសង្គមមនុស្ស។ ព្រះជាម្ចាស់បានបង្កើតសភាពដែលស្ថិតនៅតាមកំណើតដើមនៃលក្ខណុៈភេទដើម្បីបាននាំទៅដល់ភក្តីភាពក្នុងគ្រួសារ ការសង់សម្ព័ន្ធមេត្រីរវាងប្តីនិងប្រពន្ធ ការបង្កើតកូនចៅ និងការត្រឡប់ជាសាច់តែមួយដ៏ប្រសើរ ប៉ុន្តែបាបបាននាំសភាពដែលស្ថិតនៅតាមកំណើតដើមនៃលក្ខណុៈភេទវាបានបណ្តាលឲ្យមានភាពអាប់ឱន ផ្លាស់ប្តូរសេចក្តីស្រឡាញ់ដ៏ល្អ ដែលព្រះជាម្ចាស់ចង់បានទៅជាការបំផ្លិចបំផ្លាញវិញ ដោយពួកគេនាំគ្នាបោកបញ្ឆោតខ្លួនឯងថា ពួកគេបានគេនចំណេញលើដៃគូរស្នេហារបស់ខ្លួន។ ចំលើយដ៏សំខាន់បំផុតដែលយើងអាចលើកឡើងឆ្លើយតបទៅចំពោះការរីកដុះដាលប្រកបដោយប្រជាប្រិយភាពនៃរូបអាសគ្រាមនេះ គឺមាននៅក្នុងគោលលទ្ធិអំពីអំពើបាបដែលមានបង្រៀននៅក្នុងព្រះ

គម្ពីរ។ ក្នុងនាមជាមនុស្សមានបាប យើងបានបំផ្លាញស្នាព្រះហស្តដ៏ល្អឥតខ្ចោះរបស់ព្រះអង្គ ព្រមទាំងបានផ្លាស់ប្រែការរួមរក្ស័ទៅជាការសកម្មភាពម្យ៉ាង ដើម្បីគ្រាន់តែសប្បាយខាងរូបសាច់ប៉ុណ្ណោះ។ យើងបានកាត់ផ្តាច់ការរួមភេទចេញពីជីវិតអាពាហ៍ពិពាហ៍។

បន្ថែមពីលើនេះ យើងត្រូវចាំថា នៅក្នុងសេដ្ឋកិច្ចទីផ្សាសេរី ការឲ្យរង្វាន់ដល់ពួកអ្នកដែលបានបង្កើតនូវផលិតផលអ្វីមួយគឺជារឿងដែលទាក់ទាញបំផុត។ ពួកអ្នកដែលលក់រូបអាសគ្រាមដឹងថា ពួកគេមានជោគជ័យក្នុងការលក់ដោយគ្រាន់តែនាំផលិតផលរបស់ពួកគេទៅកាន់អ្នកដែលមានគំនិតអសីលធម៌ផ្លូវភេទ។ ដូច្នេះប្រសិនបើគ្មានការទប់ស្កាត់ខាងផ្លូវច្បាប់កាលពីជំនាន់មុននោះទេ នោះបច្ចុប្បន្ននេះ ពួកជនអាសអាភាសនឹងមានសេរីភាពក្នុងការលក់រូបអាសគ្រាមរបស់ពួកគេដោយសេរី គ្មានការរារាំងអ្វីទាំងអស់។ លើសពីនេះទៀតពួកគេបានដាក់គ្រឹះនៃការវាយលុកទីផ្សាររបស់ពួកគេតាមរយៈការវាយតំលៃយ៉ាងនេះថា ប្រសិនបើពួកគេអាចទាក់ទាញមនុស្សម្នាក់ឲ្យប្រើប្រាស់រូបអាសគ្រាមនៅដំបូងដែបាន នោះថ្ងៃក្រោយអ្នកនោះនឹងចង់មើលរូបនោះដោយខ្លួនឯង ហើយរហូតដល់ត្រូវការសំភារៈផ្លូវភេទបន្ថែមទៀត ដើម្បីទុកជាមធ្យោបាយមួយឲ្យបានសំរេចអារម្មណ៍ផ្លូវភេទនោះ។

ឯលទ្ធិផលនោះគឺ ក្នុងនិស្ស័យបាបរបស់យើង មនុស្សប្រុស តែងចាប់អារម្មណ៍ចំពោះរូបអាសគ្រាម ហើយភាគរយច្រើនបំផុតរបស់មនុស្សប្រុសគឺផ្អែកលើរូបអាសគ្រាម ដើម្បីឲ្យមានអារម្មណ៍ផ្លូវភេទ បំពេញផ្លូវភេទ និងសំរេចបំណងក្នុងការរស់នៅរបស់ខ្លួន។ ពួកគេបានបោកបញ្ឆោតខ្លួនឯងដោយគិតថា នេះគឺជាការល្អសំរាប់ជីវិត។ ការស្រាវជ្រាវខាងឱសថសាស្ត្របានបង្ហាញថា លំហូរនៃអ័រម៉ូនដែលបង្កើតឲ្យមានភាពត្រេកត្រអាលនៅក្នុងខួរក្បាលមានការកើនឡើង នៅពេលគេមើលរូបអាសគ្រាម។ ប៉ុន្តែទោះយ៉ាងនេះក្តី នៅពេលដែលរូបអាសគ្រាមដែលម្នាក់ធ្លាប់មើល តែបែរជាលែងនាំឲ្យមានអ័រម៉ូនហូរដែលនាំឲ្យកើតមានភាពត្រេកត្រអាលនៅក្នុងខួរក្បាលទៀតហើយនោះ ដូច្នេះគេចាំបាច់ត្រូវការមើលរូបភាពអាសអាភាសដែលមានភាពអនាចារជាងមុន ដើម្បីរក្សានូវលំហូរនៃអ័រម៉ូននៅក្នុងទីផ្ចោចនៃអារម្មណ៍ស្រើបស្រាលនៅក្នុងខួរក្បាលរបស់យើងដែរ។ ដោយមិនដឹងថាមានអ្វីកើតឡើងទេនោះ នោះមនុស្សប្រុសនឹងធ្លាក់ចូលទៅក្នុងអន្ទាក់នៃអំពើបាបកាន់តែជ្រៅឡើងៗមិនខាន ហើយក៏នឹងស្វែងរកភាពត្រេកត្រអាលតាមរយៈរូបអាសគ្រាមកាន់តែច្រើនឡើងដែរ ដោយព្យាយាមកុហក់ខ្លួនឯងថា នេះគឺជារឿងធម្មតា មិនមានបញ្ហាអ្វីទេ ដែលទាំងអស់នេះចាប់ផ្តើមកើតឡើងនៅពេលដែលពួកគេមានអារម្មណ៍ស្រើបស្រាល នៅពេលបានឃើញរូបអាសគ្រាមលើកដំបូង។

សព្វថ្ងៃនេះ ដោយសារប្រព័ន្ធអ៊ីនធឺណែត វាបានបង្កើតនូវប្រវត្តិសាស្ត្រមួយថ្មី ដោយយុវវ័យម្នាក់ៗអាចមើលគេហទំព័រអាសអាភាសច្រើនរាប់មិនអស់នៅក្នុងបន្ទប់គេងរបស់ខ្លួន ដែលនេះនាំទៅដល់អារម្មណ៍ស្រើបស្រាល ត្រេតត្រអាលនិងខូចអាក្រក់។

រូបអាសគ្រាមគឺជាបញ្ហាដ៏ធំបំផុតមួយដែលជ្រាតចូលទៅក្នុងជីវិតអាពាហ៍ពិពាហ៍ដ៏បរិសុទ្ធនិងការរួមភេទដែលត្រឹមត្រូវគឺនៅពេលដែលអ្នកទាំងពីរ (មនុស្សនិងមនុស្សស្រី) បានក្លាយជាសាច់តែមួយ។ ការប្រព្រឹត្តអសីលធម៌ខាងផ្លូវភេទជាងការប្រកាន់យកភាពបរិសុទ្ធ ការបំពេញភាពត្រេកត្រអាលនៃអង្គជាតិដ៏លើសលប់ និងភាពពុករលួយនៃថាមពលរួមភេទ នឹងបំផ្លាញនូវទស្សនៈនៃជីវិតអាពាហ៍ពិពាហ៍ ហើយនឹងនាំទៅដល់គ្រោះថ្នាក់រាប់មិនអស់មិនខាន មិនតែប៉ុណ្ណោះវាក៏នឹងប៉ះពាល់ដល់ភក្តីភាពនៃអាពាហ៍ពិពាហ៍ និងចំណងគ្រួសារផងដែរ។

This is an abridged translation of "The seduction of pornography and the integrity of Christian marriage part 1" by Al Mohler. If you wish to read the English, please go to http://www.albertmohler.com/2005/06/08/the-seduction-of-pornography-and-the-integrity-of-christian-marriage-part-one/